**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder

**ក្រសួងទេសចរណ៍**

លេខ ៣៤៦ សសណ.ទទ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៦

**ជម្រាបជូន**

**លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**កម្មវត្ថុ**: ករណីសំណើសុំបង្កើតបណ្ណាល័យ និងការិយាល័យព័ត៌មាននៅតំបន់ «ក៣» ផ្ទះតាម៉ុក ផ្ទះកណ្តាល ភ្នំដងរែក។

**យោង** : លិខិតចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៦ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកនាយក** ជ្រាបថា ក្រសួងទេសចរណ៍សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំប្រឹងប្រែងសាងសង់ និងជួសជុលអតីតផ្ទះតាម៉ុក ផ្ទះកណ្តាលលើភ្នំដងរែក។ តបតាមសំណើរបស់លោកនាយក ក្រសួងទេសចរណ៍អនុញ្ញាតជាគោលការណ៍ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាបង្កើតបណ្ណាល័យ និងការិយាល័យព័ត៌មាននៅតំបន់ «ក៣» ផ្ទះតាម៉ុក ផ្ទះកណ្តាល ភ្នំដងរែក ដើម្បីបើកបម្រើជូនភ្ញៀវទេសចរជាតិនិងអន្តរជាតិបានអាន និងទស្សនាស្វែងយល់ពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែង។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវធ្វើរបាយការណ៍ពីវឌ្ឍនភាពនៃដំណើរការបណ្ណាល័យ និងការិយាល័យព័ត៌មានមកក្រសួងទេសចរណ៍ឲ្យបានទៀងទាត់ជាទៀងរាល់៣ខែម្តង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកនាយក** ចាត់ចែង តាមការគួរ។

សូម **លោកនាយក** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

ចម្លងជូន
- សាលាខេត្តឧត្តរមានជ័យ
- មន្ទីរទេសចរណ៍ខេត្តឧត្តរមានជ័យ

  «ដើម្បីជូនជ្រាប»
- ឯកសារ-កាលប្បវត្តិ

អគារលេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.mot.kh